# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

## កំណត់ហេតុ
## កិច្ចប្រជុំលើកទី១ក្រុមបច្ចេកទេស

ឆ្នាំពីរពាន់ដប់បួន ខែមករា ថ្ងៃទីម្ភៃពីរ វេលាម៉ោងប្រាំបី និងសាមសិបនាទី នៅសណ្ឋាគារ សូហ្វីតែល ភូគីត្រា រាជធានីភ្នំពេញ មានកិច្ចប្រជុំលើកទី៤ នៃក្រុមប្រឹក្សាយោបល់សម្រាប់ការងាររេដ+កម្ពុជា ក្រោមអធិបតីភាព សហប្រធាន លោកសៀក សុផាត ជាតំណាងក្រុមប្រឹក្សាយោបល់ និងលោក អ៊ុយ កាម៉ាល់ ជាតំណាងលេខាធិការដ្ឋានរេដ+កម្ពុជា។ កិច្ចប្រជុំនេះរៀបចំឡើងដោយលេខាធិការដ្ឋានរេដ+ ដោយមានអ្នកចូលរួមសរុបចំនួន ២៣នាក់ រួមមាន៖ សមាជិកក្រុមប្រឹក្សា ១៥នាក់ បុគ្គលិកលេខាធិការដ្ឋាន ៧នាក់ និងអ្នកធ្វើបទបង្ហាញពីលេខាធិការដ្ឋាន UNFCCC ១នាក់។

កិច្ចប្រជុំគឺផ្តោតទៅលើ៖ (១)ការពិនិត្យកំណត់ហេតុកិច្ចប្រជុំលើកទី៣ (២)ការពិនិត្យ និងពិភាក្សាទៅលើប្រធានបទ និងឯកសារពិភាក្សាក្នុងកិច្ចប្រជុំលើកទី៣ របស់ក្រុមការងាររេដ+កម្ពុជា (៣)ការពិនិត្យឡើងវិញពីការបំពេញតួនាទីជាក្រុមប្រឹក្សាយោបល់ផង និងជាក្រុមបច្ចេកទេសផង និង (៤)ការពិនិត្យ និងពិភាក្សាទៅលើផែនការយន្តការលំហូរព័ត៌មាន និងការផ្តល់យោបល់ត្រឡប់របស់ក្រុមប្រឹក្សាយោបល់។

<u>(ព័ត៌មានបន្ថែមសូមអាន: ឧបសម្ព័ន្ធទី០១ បញ្ជីឈ្មោះអ្នកចូលរួម និងឧបសម្ព័ន្ធទី០២ របៀបវារៈ)</u>

### មតិចាប់ផ្តើមបើកអង្គប្រជុំ

កិច្ចប្រជុំបានចាប់ផ្តើមដោយមានមតិស្វាគមន៍បើកអង្គប្រជុំ របស់សហប្រធានក្រុមប្រឹក្សាយោបល់ និងអនុប្រធានលេខាធិការដ្ឋានរេដ+កម្ពុជា។

លោកបណ្ឌិត សៀក សុផាត មានការសាទរចំពោះវត្តមានអ្នកចូលរួមនៅថ្ងៃនេះ។ លោកសង្ឃឹមថា កិច្ចប្រជុំនឹងពិភាក្សា ទៅលើផែនការប្រឹក្សាយោបល់របស់ក្រុមនីមួយៗ ដែលបានរៀបចំក្នុងវគ្គបណ្តុះ បណ្តាល ដែលបានរៀបចំសម្របសម្រួលដោយរីខូហ្វស (RECOFTC) ដើម្បីធ្វើការសម្រេចឲ្យបានឆាប់រហ័ស។

លោក អ៊ុយ កាម៉ាល បានគាំទ្រយោបល់លោកបណ្ឌិត សៀក សុផាត និងបន្ថែមចំនុចនេះទៅលើរបៀបវារៈកិច្ចប្រជុំក្រុមការងាររេដ+។ ប្រធានបទសំខាន់នៃកិច្ចប្រជុំក្រុមការងាររេដ+ នឹងមានបង្ហាញអំពី

ជម្រើសនៃការអនុវត្តគម្រោងវេជ+ទាំងបីប្រភេទគឺ៖ (១)វេជ+ផ្អែកតាមគម្រោង (Project Based) (២)វេជ+ថ្នាក់ក្រោមជាតិ និង (៣)វេជ+ថ្នាក់ជាតិ។ គម្រោងវេជ+ទាំងបីប្រភេទ សុទ្ធតែមានចំណុចវិជ្ជមាន និងអវិជ្ជមាន ដែលពាក់ព័ន្ធនឹងការចំណាយ ពេលវេលា និងវិធីសាស្ត្រនៃការអនុវត្ត។ ដូចមាននៅក្នុងឯកសារចែកជូន សមាជិកទាំងអស់នឹងអាចយល់បាន ពីភាពខុសគ្នានៃគម្រោងវេជ+ទាំងបីប្រភេទ ដូច្នេះកិច្ចប្រជុំគួរពិនិត្យ និងផ្តល់យោបល់ ថាតើគម្រោងវេជ+ប្រភេទណាមួយសមស្របបំផុតសម្រាប់កម្ពុជា។

## កិច្ចប្រជុំ

### *១. ការពិនិត្យកំណត់ហេតុកិច្ចប្រជុំលើកទី៣*

*លោក លន់ គឹមហ៊ី បានបញ្ជាក់ថា កំណត់ហេតុកិច្ចប្រជុំលើកទី៣ បានពិនិត្យ និងចុះហត្ថលេខាដោយសហប្រធានទាំងពីរ ដូច្នេះការកែសម្រួលលើកំណត់ហេតុ អាចធ្វើទៅបាននៅពេលដែលលេខាធិការដ្ឋាន ព្រាង និងផ្ញើជូនសុំយោបល់កែសម្រួល។*

### *សំណួរចម្លើយនិងកិច្ចពិភាក្សា*

*លោក វ៉ា មឿន រំលឹកថាកិច្ចប្រជុំកន្លងមក បានសម្រេចថា រាល់កិច្ចប្រជុំត្រូវមានប្រធានអង្គប្រជុំប្តូរវេនដើម្បីសម្របសម្រួលកិច្ចប្រជុំ តើការសម្រេចនេះត្រូវបន្តអនុវត្ត ឬ លែងមានសុពលភាព?*

*ការសម្រេចនេះបានអនុវត្ត នៅកិច្ចប្រជុំលើកទីពីរ ប៉ុន្តែប្រធានអង្គប្រជុំប្តូរវេន( លោកវ៉ា មឿន) អវត្តមាន សមាជិកជំនួសសុំ ប្រធានក្រុមប្រឹក្សាយោបល់( លោក សៀក សូផាត)ជួយសម្របសម្រួល។ ដោយសារសមាជិកក្រុមប្រឹក្សាយោបល់ខ្លះ ហាក់ដូចជាពុំមានការជឿជាក់សមត្ថភាពខ្លួន ក្នុងការដឹកនាំកិច្ចប្រជុំ និងម្យ៉ាងទៀតអង្គប្រជុំមិនបានចាត់តាំងប្រធានអង្គប្រជុំប្តូរវេន ដូច្នេះការសម្រេចនេះមិនបានអនុវត្តរហូតមក។ ប៉ុន្តែវាជាការប្រសើរ ប្រសិនបើការសម្រេចនេះបានអនុវត្ត និងដំណើរការបានល្អ ក្រុមប្រឹក្សាយោបល់ នឹងមានភាពរឹងមាំ ដឹកនាំ សម្របសម្រួល កត់ត្រា និងរៀបចំកិច្ចប្រជុំដោយខ្លួនឯងដោយមិនបាច់ពឹងផ្អែកលើលេខាធិការដ្ឋានវេជ+ជួយសម្របសម្រួលរាល់កិច្ចប្រជុំ។*

*លោក សៀក សូផាត ផ្តល់យោបល់ថា គំនិតដែលបានលើកឡើងពិតជាមានសារសំខាន់។ ក្រុមប្រឹក្សាយោបល់ ត្រូវធានាថាអាចដំណើរការ និងអនុវត្តបានដោយឯករាជ្យ ដោយមិនចាំបាច់មានជំនួយសម្របសម្រួលពីលេខាធិការដ្ឋាន។ ដូច្នេះ ត្រូវផ្លាស់ប្តូរ អ្នកដឹកនាំអង្គប្រជុំ ក្នុងកិច្ចប្រជុំនីមួយៗ។លោក*

សៀក សូផាត បានលើកសំណួរថា ប្រសិនបើក្រុមក្រុមប្រឹក្សាយោបល់ ត្រូវការលេខាម្នាក់ ដើម្បីជួយការងារនេះ តើលេខាធិការដ្ឋាន អាចជួយផ្តល់ថវិកាគាំទ្របានដែរឬទេ?

លោក វ៉ា មឿន បានបញ្ជាក់ថា ការជ្រើសរើសប្រធានសម្របសម្រួលកិច្ចប្រជុំ តែងមានការលំបាក សមាជិកខ្លះមានការរវល់ច្រើន និងខ្លះទៀតគិតថាពុំមានសមត្ថភាព ដូច្នេះប្រសិនបើមិនចាំបាច់ យើងមិនបាច់ឲ្យមានប្រធានសម្រាប់កិច្ចប្រជុំទេ។

កញ្ញា តេង រិទ្ធីនី ផ្តល់មតិថា យើងគួរតែមានប្រធានប្តូរវេនសម្របសម្រួលអង្គប្រជុំ ដើម្បីជានាឲ្យមានការចូលរួម ផ្តល់ឱកាសដល់ការអនុវត្តការសម្របសម្រួល ពង្រឹងសមត្ថភាព និងមានឯកភាព នៅពេលដែលលេខាធិការដ្ឋានដកខ្លួនចេញ ។

លោកសៀក សូផាត និង លោក អ៊ុយ កាម៉ាល បានគាំទ្រយោបល់ កញ្ញា រិទ្ធីនី។ លោក អ៊ុយ កាម៉ាល ក៏បានបន្ថែមថា កន្លងមកយើងបានបោះឆ្នោតជ្រើសរើសប្រធាន អនុប្រធាន និងលេខា សម្រាប់ក្រុមប្រឹក្សាយោបល់ ប៉ុន្តែមិនទាន់បានកំណត់អាណត្តិ(ប៉ុន្មានឆ្នាំ)។ ក្រុមប្រឹក្សាយោបល់ ក៏មានរចនាសម្ព័ន្ធមួយច្បាស់លាស់រួចហើយដែរ ដោយឡែកលេខាធិការដ្ឋាន គឺមានតួនាទី ជាអ្នកជួយរៀបចំសិក្ខាសាលា ឬ កិច្ចប្រជុំប៉ុណ្ណោះ។ ការសម្រេចឲ្យមានប្រធានប្តូរវេនដឹកនាំអង្គប្រជុំជាការប្រសើ ដើម្បីឲ្យសមាជិកមានឱកាសរៀនសូត្រពីការរៀបចំ និងដឹកនាំកិច្ចប្រជុំ ចំណែកលេខាធិការដ្ឋាន គ្រាន់តែជួយកោះអញ្ជើញ និងរៀបចំកិច្ចប្រជុំ។ ក្នុងកិច្ចប្រជុំនីមួយៗ ប្រធានប្តូរវេនដឹកនាំអង្គប្រជុំ អាចស្នើសុំសមាជិកម្នាក់ធ្វើកំណត់ត្រា និងរបាយការណ៍ផ្សេងៗ ប៉ុន្តែប្រធាននឹងជួយពិនិត្យកំណត់ត្រា និងរបាយការណ៍ ឬ ការសម្រេចនានា ដែលនឹងដាក់ជូនលេខាធិការដ្ឋាន ដើម្បីពិនិត្យ និងសម្រេច។ ចំពោះផែនការប្រឹក្សាយោបល់របស់ក្រុមនីមួយៗ ដែលបានដាក់ស្នើសុំគាំទ្រថវិកា គឺនៅមិនទាន់ដឹងច្បាស់ពីរបៀបនៃការផ្តល់ និងការចាយវាយថវិកានៅឡើយទេ។

ចុងបញ្ចប់កិច្ចប្រជុំ បានសម្រេចឲ្យមានប្រធានប្តូរវេនសម្របសម្រួលអង្គប្រជុំ។ ការជ្រើសរើសនឹងយកតាមលំដាប់លេខរៀងនៃបញ្ជីឈ្មោះក្រុមប្រឹក្សាយោបល់ ដែលមានភ្ជាប់ក្នុងឧបសម្ព័ន្ធទី០១។ សហប្រធាននឹងជួយសម្របសម្រួលបន្ថែម ប្រសិនបើប្រធានប្តូរវេន នៅមិនទាន់មានសមត្ថភាពល្អ។

លោកលន់ គឹមហ៊ី បានសួរបញ្ជាក់ថា បើមានប្រធានប្តូរវេនសម្របសម្រួលអង្គប្រជុំ តើសហប្រធានអង្គប្រជុំ នឹងមានតួនាទីយ៉ាងដូចម្តេច?

ពាក់ព័ន្ធនឹងបញ្ហានេះ លោក អ៊ុយ កាម៉ាល ក៏បានលើកសំណួរថា ហាក់ដូចជាមិនទំនង ដែលលោកជាសហប្រធានអង្គប្រជុំផង និងជាអនុប្រធានលេខាធិការដ្ឋានផង ជាអ្នកចុះហត្ថលេខា លើ

*កំណត់ហេតុកិច្ចប្រជុំ ដែលត្រូវដាក់ជូនលេខាធិការដ្ឋាន។ ដូច្នេះ លោកបានសំណូមពរថា កំណត់ហេតុកិច្ចប្រជុំ គួរមានត្រឹមតែហត្ថលេខា សហប្រធានតំណាងក្រុមប្រឹក្សាយោបល់ជាការត្រឹមត្រូវ។*

*បញ្ហានេះកិច្ចប្រជុំ បានសម្រេចថា កំណត់ហេតុនៃកិច្ចប្រជុំ នឹងចុះហត្ថលេខាតែអ្នកធ្វើកំណត់ត្រា និងសហប្រធានតំណាងក្រុមប្រឹក្សាយោបល់ជាការស្រេច។*

### *២. ការពិនិត្យ និងពិភាក្សាទៅលើប្រធានបទ និងឯកសារពិភាក្សា នៃកិច្ចប្រជុំក្រុមការងាររេដ+កម្ពុជា*

*លោក លន់ គឹមហ៊ី បានធ្វើបទបង្ហាញ ដែលផ្តោតទៅលើប្រធានបទរេដ+នៅថ្នាក់ផ្សេងៗគ្នា៖ គឺ រេដ+ផ្អែកតាមគម្រោង(Project) រេដ+ថ្នាក់ក្រោមជាតិ (Subnational) និង/ឬ រេដ+ថ្នាក់ជាតិ (National) (ព័ត៌មានបន្ថែមសូមអានឧបសម្ព័ន្ធទី០៣)*

### *ការពិភាក្សា និងផ្តល់យោបល់៖*

*ការពិភាក្សាបានផ្តោតទៅលើការចែករំលែកព័ត៌មាន និងការទទួលយកផ្តល់ព័ត៌មានត្រឡប់ពីក្រុមនីមួយៗ។ សមាជិកភាគច្រើន មិនទាន់បានចែកចាយព័ត៌មានទៅក្រុមរបស់ខ្លួនទេ ដោយសារៈ*

- *បារម្ភណ៍ពីការអនុញ្ញាតក្នុងការផ្សព្វផ្សាយ ទៅក្រុមរបស់ខ្លួន ព្រោះពុំមានលិខិតបញ្ជាក់ពីអត្តសញ្ញាណរបស់ខ្លួន*
- *មានការលំបាកក្នុងការផ្សព្វផ្សាយ ដោយសារចំណេះដឹងរបស់ខ្លួននៅមានកម្រិត*
- *មិនទាន់មានយន្តការផែនការច្បាស់លាស់សម្រាប់ក្រុម*
- *ពុំមានថវិកាគាំទ្រសកម្មភាពចែកចាយព័ត៌មាន ពិគ្រោះយោបល់ និងព័ត៌មានត្រឡប់។*

*សមាជិកក្រុមប្រឹក្សាយោបល់ ព្រួយបារម្ភណ៍ថា ប្រសិនបើការត្រៀមលក្ខណៈ និងការអនុវត្ត រេដ+មានភាពយឺតយ៉ាវ ព្រៃឈើនឹងអាចបាត់បង់អស់ ដោយសារសកម្មភាពបទល្មើសបច្ចុប្បន្ន ដែលជាហេតុនាំឲ្យពួកគាត់មានភាពស្ទាក់ស្ទើរ និងមានភាពស្រពិចស្រពិល ក្នុងការផ្សព្វផ្សាយអំពីរេដ+។*

*លោក អ៊ុយ កាម៉ាល បានពន្យល់បន្ថែមថា កន្ទងមកកម្ពុជា បានតាំងចិត្តអនុវត្ត ការកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ តាមពិធីសារក្យូតូ (Kyoto Protocol) ដែលជាឯកសាច្បាប់មួយនៅក្នុងសន្និសីទកំពូលស្តីពីការប្រែប្រួលអាកាសធាតុរបស់អង្គការសហប្រជាជាតិ ដែលហៅក្របខណ្ឌសហប្រជាជាតិ ស្តីពីការប្រែប្រួលអាកាសធាតុ(UNFCCC)។ ក្រោមពិធីសារក្យូតូ គឺមានការបែងចែកបណ្តាប្រទេស ជាពិសេសប្រទេសឧស្សាហកម្ម ត្រូវមានកាតព្វកិច្ចក្នុងការកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ ដែលរួមមានបីយន្តការៈ (១)យន្តការអភិវឌ្ឍន៍ស្អាត(CDM) (២)យន្តការអភិវឌ្ឍន៍រួមគ្នា និង(៣)យន្តការដូរញដូរក្នុងចំណោម*

ប្រទេសអភិវឌ្ឍន៍។ ជាអនុសាសន៍ នៅក្រោមពិធីសារក្យូតូ អ្វីដែលសមស្របបំផុតសម្រាប់អនុវត្តន៍នៅកម្ពុជាកន្លងមក គឺយន្តការអភិវឌ្ឍន៍ស្អាត ដែលនៅក្នុងនោះគម្រោងទាក់ទងនឹងព្រៃឈើក៏បានដាក់នៅក្រោមយន្តការអភិវឌ្ឍន៍ស្អាតនេះផងដែរ ប៉ុន្តែមិនអាចធ្វើទៅបាន ដោយសារតែនិយមន័យ និងលក្ខខណ្ឌ មួយចំនួន។ ម្យ៉ាងទៀតនៅក្នុងគម្រោង CDM គឺចែងមកមិនអាចអនុវត្តន៍បាន។ ក្រោយមកក្រោមយន្តការUNFCCC ក្រោមយន្តការអភិវឌ្ឍន៍ស្អាត ក៏បានបង្កើតគម្រោងរេដ+នេះឡើង។ នៅក្នុងកិច្ចប្រជុំ COPទី១៦ នៅទីក្រុងបាលី ប្រធានាធិបតីឥណ្ឌូនេស៊ីបានមានប្រសាសន៍ថា ព្រៃឈើមិនមែនជាទ្រព្យសម្បត្តិ របស់ជនជាតិណាមួយនោះទេ ប៉ុន្តែជាសម្បត្តិពិភពលោក។ មានន័យថាព្រៃនៅប្រទេសគាត់មិនមែនត្រូវតែការពារដោយប្រជាជនឥណ្ឌូនេស៊ីនោះទេ តែត្រូវតែការពារដោយពិភពលោក និងមានការបរិច្ចាក ដែលនេះជាលទ្ធផលនាំឲ្យមានកម្មវិធីរេដ+កើតឡើង។ នៅក្នុងកិច្ចប្រជុំCOPទី១៩ មានការសម្រេចជាច្រើន ដែលគាំទ្រដល់កម្មវិធីរេដ+ ហើយការសម្រេចទាំងនេះ មានទំនោរទៅរកការអនុវត្តរេដ+ នៅថ្នាក់ជាតិ ឬ នៅថ្នាក់ក្រោមជាតិ។

កន្លងមកកម្ពុជាយើង បានអនុវត្តគម្រោងរេដ+នៅឧត្តរមានជ័យ និងគម្រោងរេដ+នៅសីម៉ា គឺអនុវត្តតាមវិធីសាស្ត្រ និងយន្តការទីផ្សារកាបូនស្ម័គ្រចិត្ត ដែលការអនុវត្តគម្រោងនីមួយៗ អាចមានការប្រែប្រួល និងខុសគ្នាពីមួយទៅមួយ។ ប្រសិនបើយើងសម្រេចថា អនុវត្តរេដ+នៅថ្នាក់ជាតិ ឬ ក្រោមជាតិ គឺយើងត្រូវអនុវត្ត ទៅតាមវិធីសាស្ត្រ និងយន្តការ UNFCCC ដែលទាមទារនូវចំណេះដឹង និងថវិកា ក្នុងការរៀបចំឲ្យបានគ្រប់តម្រូវការដែលបានកំណត់។

លោក អ៊ុយ កាម៉ាល ក៏បានបន្ថែមថា ទាក់ទងនឹងថវិកាទីផ្សារកាបូន គឺមានជប៉ុន ចិន និងកូរ៉េ។ ប៉ុន្តែក្រោមយន្តការកាបូនរួមគ្នា (JCM/Joint Credit Mechanism) មានតែជប៉ុនមួយទេ ដែលយកពិធីសារក្យូតូមកអនុវត្ត ដោយចុះហត្ថលេខាទ្វេភាគីជាមួយបណ្តាប្រទេសជាដៃគូ។ បច្ចុប្បន្ន ជប៉ុនបានចុះហត្ថលេខាជាមួយប្រទេសមួយចំនួនដូចជា៖ វៀតណាម បង់ក្លាដេស ម៉ុងហ្គោលី ឡាវ ។ល។ ដោយឡែកកម្ពុជាកំពុងរៀបចំឯកសារ ដែលការអនុវត្តត្រូវមានការពិភាក្សាឲ្យបានច្បាស់លាស់ ពាក់ព័ន្ធនឹងការដាក់បញ្ចូលទាំងវិស័យព្រៃឈើក្នុងការអនុវត្ត។ នៅពេលប្រទេសកម្ពុជា ចុះហត្ថលេខា ជាមួយជប៉ុនក្រោមយន្តការ JCM មិនមែនមានតែវិស័យព្រៃឈើនោះទេ វិស័យនានាក៏ត្រូវចូលរួមចំណែក ដើម្បីជួយកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ផងដែរ។ ក្នុងករណីកម្ពុជាចុះហត្ថលេខាJCM ជប៉ុននឹងផ្តល់ថវិកាសម្រាប់ជួយគាំទ្រសម្រាប់អនុវត្តគម្រោងរេដ+។ ដូច្នេះ ថវិកាទីផ្សារកាបូន ជប៉ុនមានយន្តការមួយ កូរ៉េក៏មានយន្តការមួយ ហើយប្រទេសចិនក៏ចង់បង្កើតទីផ្សារកាបូនមួយផងដែរ។

លោក គឹម ណារុង្គ៖ កម្ពុជាស្ថិតក្នុងដំណាក់កាលត្រៀមលក្ខណៈរេដ+ ដូច្នេះការអនុវត្តគម្រោងសាកល្បង នៅឧត្តរមានជ័យ និងនៅសីម៉ា ជាការរួមចំណែកយ៉ាងសំខាន់ ដើម្បីផ្តល់បទពិសោធន៍ទាក់ទងនឹងការអនុវត្តនៅមូលដ្ឋាន ប្រសិនបើយើងមិនមានគម្រោងសាកល្បងនេះទេ យើងនឹងមិនអាចឆ្លុះបញ្ចាំងនូវរាល់បញ្ហា និងការលំបាកដែលកើតឡើងក្នុងពេលអនុវត្តន៍នោះទេ។ ឧទាហរណ៍៖ យន្តការចែករំលែកផលប្រយោជន៍ យើងមានការស្ទាក់ស្ទើរក្នុងការសម្រេច ដោយសារគម្រោងមិនទាន់ដល់ដំណាក់កាលលក់កាបូន និងបានសាកល្បងចែករំលែកផលប្រយោជន៍នៅឡើយ។

## ៣. បទបង្ហាញស្តីពី UNFCCC រេដ+

លោក Dirk Nemitz មន្ត្រីកម្មវិធីនៃលេខាធិការដ្ឋានប្រែប្រួលអាកាសធាតុ នៃអង្គការសហប្រជាជាតិ ប្រទេសអាល្លឺម៉ង់ បានធ្វើបទបង្ហាញ ដែលផ្តោតទៅលើ៖ រចនាសម្ព័ន្ធនៃរេដ+ និងសេចក្តីសម្រេចពីសន្និសីទបណ្តាប្រទេសជាភាគី។
(ព័ត៌មានបន្ថែមសូមអានឧបសម្ព័ន្ធទី០៤)

## សំណួរ និងចម្លើយ

សំណួរទី១៖ ក្នុងកិច្ចប្រជុំ COP តើមានសំណួរផ្តោតលើសិទ្ធិជនជាតិដើមភាគតិចដែរឬទេ?

ប្រហែលជាពាក់កណ្តាលនៃប្រទេសដែលបានចូលរួម បានសំណូមពរឲ្យ មានការបញ្ចូលនូវចំណុចនេះ។ តួយ៉ាងនៅ ប្រទេសហ្វីលីពីន ដែលមានតំណាងមួយជាជនជាតិដើមភាគតិច ជាសហប្រធាននៃកិច្ចប្រជុំ។ អ្នកចូលរួម គឺជាតំណាងប្រទេស និងតំណាងអង្គការនានា។ ការពិភាក្សាគឺធ្វើឡើងនៅក្នុងវេទិកាបើកទូលាយជាច្រើនដោយឡែកពីគ្នា ប៉ុន្តែមិនមែនពិភាក្សានៅក្នុងកិច្ចប្រជុំរួមនោះទេ។

សំណួរទី២៖ តើប្រទេសណាខ្លះដែលទទួលស្គាល់ និងឯកភាពទៅលើលក្ខខណ្ឌ ឬ គោលការណ៍ណែនាំ ដែលបានសម្រេចដោយ UNFCCC? តើគោលការណ៍ណែនាំនោះ មានសុពលភាពប៉ុន្មានឆ្នាំ ដែលតម្រូវឲ្យអនុវត្តន៍តាម? តើមានចំណុចឯកភាពណាខ្លះ ពាក់ព័ន្ធនឹងការផ្តល់ថវិកាដល់ប្រទេសកំពុងអនុវត្តន៍រេដ+? និងមានចំណុចណាខ្លះដែលមិនទាន់មានការឯកភាពគ្នា?

ចំពោះគោលការណ៍ណែនាំទៅលើការវាស់វែង ត្រូវមានការយល់ព្រមពីប្រទេសជាសមាជិកទាំង៩៤ បើមិនដូច្នោះទេ លេខាធិការដ្ឋាន UNFCCC នឹងសាកសួរយោបល់ប្រទេសដែលមិនយល់ព្រម។ នៅឆ្នាំ២០០៧ យោងតាមកិច្ចព្រមព្រៀងកេនគូន (CANCUN) ក៏បានពិភាក្សាលើការបង់ថវិកានោះដែរ។ ចំពោះការអនុវត្ត ស្ថិតក្នុងការពិភាក្សានៅឡើយ មិនទាន់បានសម្រេចអ្វីនោះទេ។ មានភាពប្រឈមពីរ

គឺ (១)ការបង្កើតកិច្ចព្រមព្រៀងស្តីពីការប្រែប្រួលអាកាសធាតុថ្មី និង(២)ការវាស់វែងកម្រិតយោង។ មានប្រទេសតិចតួចបំផុតដែលបានវាស់កម្រិតយោង និងមានការលំបាកដោយសារត្រូវការបច្ចេកទេសពាក់ព័ន្ធនឹងប្រព័ន្ធធានាសុវត្ថិភាព និងការវាស់វែងព្រៃឈើ ដែលជាហេតុធ្វើឲ្យវឌ្ឍនភាព នៃការអនុវត្តរេដ+នៅប្រទេសនានាមានភាពខុសគ្នា។ ប្រទេសកម្ពុជា គឺស្ថិតនៅក្នុងជំហានទី១នៅឡើយទេ។

សំណួរទី៣៖ យើងបានដឹងថាថវិការេដ+អាចនឹងកំណត់បានច្បាស់រហូតដល់ឆ្នាំ២០២០ ស្របពេលជាមួយគ្នានេះ ការបាត់បង់ព្រៃឈើកំពុងបន្ត និងមានការកើនឡើង។ ដូច្នេះ តើ UNFCCC មានថវិកាជួយគាំទ្រគម្រោងតូចៗ ដើម្បីទប់ស្កាត់បញ្ហាបាត់បង់ព្រៃឈើដែរឬទេ?

ជាទូទៅប្រទេសនីមួយៗ មានតួនាទីសំខាន់ក្នុងការពិនិត្យ និងពិចារណាទៅលើការផ្តល់ថវិកាអនុវត្តរេដ+នៅប្រទេសរបស់ខ្លួន ជាពិសេសការផ្តល់ទៅឲ្យសហគមន៍ផងដែរ ដើម្បីចូលរួមទប់ស្កាត់បញ្ហាបាត់បង់ព្រៃឈើ។ UNFCCC ពុំមានតួនាទីធ្វើកិច្ចការងារផ្ទាល់ជាមួយនឹងការទប់ស្កាត់បញ្ហាបាត់បង់ព្រៃឈើនោះទេ។ បញ្ហានេះ តម្រូវឲ្យប្រទេសនីមួយៗជាភាគីអនុវត្តត្រូវគិតគូរពិចារណាទៅតាមគោលនយោបាយរបស់ខ្លួន ។

សំណួរទី៤៖ សូមជួយបកស្រាយបញ្ជាក់ ព្រោះថារហូតដល់ឆ្នាំ២០២០ ទើបមានថវិកាឥណទានកាបូនពីយន្តការ UNFCCC ប៉ុន្តែបច្ចុប្បន្នគម្រោងរេដ+នៅឧត្តរមានជ័យ និងនៅសីម៉ា មានទីផ្សារកាបូនតូចៗចង់ទិញ។ សំណួរសួរថា តើថវិកាអ្នកទិញបានមកពីណា? ថវិកាដែល UNFCCC មានប្រភពមកពីណា?

UNFCCC គឺមិនមែនជាស្ថាប័នផ្តល់ថវិកានោះទេ ប្រភពថវិកាគឺមូលនិធិអាកាសធាតុបៃតង (Green Climate Fund) ដែលធ្វើការពិនិត្យរាល់ការអនុវត្តគម្រោងនីមួយៗ។ នៅក្នុងឆ្នាំ២០០៧ គេបានពិភាក្សារួចហើយថានឹងបន្តផ្តល់មូលនិធិទៅលើការអនុវត្តជំហានទី៣។ ចំពោះគម្រោងតូចៗ គឺមានតាំងពីឆ្នាំ២០០២ ហើយចំពោះUNFCCC គឺគេផ្តោតទៅលើគម្រោងថ្នាក់ជាតិ និងគម្រោងថ្នាក់ក្រោមជាតិ ជាជាងគម្រោងតូចៗ។

សំណួរទី៥៖ ការដាក់ជូនកម្រិតគោល(យោង)របស់ប្រទេសនីមួយៗទៅ UNFCCC តើត្រូវធ្វើនៅពេលណា និងដោយរបៀបណា?

រៀងរាល់ឆ្នាំ ប្រទេសនីមួយៗអាចដាក់ជូនកម្រិតគោល(យោង)ទៅ UNFCCC ។ ចំពោះគោលការណ៍ណែនាំ ពាក់ព័ន្ធនឹងកម្រិតគោល គឺគិតជាតោន $CO_2$។ ចំពោះពេលវេលានៃការដាក់ជូនកម្រិតគោលទៅ UNFCCC អាស្រ័យលើប្រទេសផ្ទាល់ខ្លួនជាអ្នកកំណត់ ទៅតាមស្ថានភាព និងសមត្ថភាព។

កម្រិតគោល គឺគេពិនិត្យទៅលើប្រវត្តិនៃការបាត់បង់ព្រៃឈើ ដោយផ្តោតលើទំហំផ្ទៃដី និង ការថយចុះគុណភាពព្រៃឈើ ដើម្បីវាស់វែងកម្រិត និងនិន្នាការនៃការបាត់បង់ព្រៃឈើ ពីមួយឆ្នាំទៅមួយឆ្នាំ និងជាបន្តបន្ទាប់។ ការអនុវត្តរេដ+ ប្រសិនបើការវាស់វែង ដោយពិនិត្យទាំងការកើនឡើង និងការថយចុះធៀបនឹងកម្រិតគោល មានលទ្ធផលវិជ្ជមាន នោះយើងនឹងទទួលបានថវិកាលើកទឹកចិត្ត ផ្ទុយមកវិញបើមានលទ្ធផលអវិជ្ជមាន នោះមិនទទួលបានថវិកាលើកទឹកចិត្តពីការអនុវត្តរេដ+នោះទេ។

សំណួរទី៦៖ ប្រសិនបើការបាត់បង់ព្រៃឈើបានថយចុះ តែប្រព័ន្ធជានាសុវត្ថិភាពមិនបានគោរព តើអាចទទួលបានថវិកាលើកទឹកចិត្តពីការអនុវត្តរេដ+ដែរឬទេ?

អាស្រ័យទៅលើកិច្ចព្រមព្រៀងទ្វេភាគី ក៏ប៉ុន្តែជាធម្មតាគ្មានប្រទេសណាមួយយល់ព្រមផ្តល់ថវិកាលើកទឹកចិត្តនោះទេ ប្រសិនបើមិនបានគោរពប្រព័ន្ធជានាសុវត្ថិភាពឲ្យបានត្រឹមត្រូវ។

## ៤.ការពិនិត្យឡើងវិញ ពីការបំពេញតួនាទីជាសមាជិកក្រុមប្រឹក្សាយោបល់ផង និងក្រុមបច្ចេកទេសផង

មានការលើកឡើងពីការព្រួយបារម្ភណ៍ពីបញ្ហាពេលវេលា និងសមត្ថភាពរបស់សមាជិក ដែលបំពេញតួនាទីជា ក្រុមប្រឹក្សាយោបល់ផង និងក្រុមបច្ចេកទេសផង។ ដោយឡែក សមាជិកដែលបានស្មគ្រចិត្ត បានលើកយោបល់ថា អាចចាត់ចែងពេលវេលារបស់ខ្លួនបាន ដើម្បីបំពេញតួនាទីជាសមាជិកក្រុមទាំងពីរ។ ម្យ៉ាងវិញទៀត បើរកសមាជិកថ្មីមកជំនួស តើមានដំណើរការជ្រើសរើសដោយរបៀបណា ដើម្បីអាចទទួលយកបាន និងមានការទទួលស្គាល់ពីអ្នកពាក់ព័ន្ធ។ បញ្ហានេះ អាចនឹងបន្តពិភាក្សានៅកិច្ចប្រជុំលើកក្រោយ ឬ សុំយោបល់ពីកិច្ចប្រជុំក្រុមការងាររេដ+។

## ៥. ការពិនិត្យ និងពិភាក្សាទៅលើផែនការយន្តការលំហូរព័ត៌មាន និងការផ្តល់យោបល់ត្រឡប់ របស់ក្រុមប្រឹក្សាយោបល់

ដោយហេតុថា ផែនការ និងថវិកា សម្រាប់គាំទ្រដល់សកម្មភាពចែករំលែក និងប្រមូលព័ត៌មានត្រឡប់របស់ក្រុមនីមួយៗ មានទំហំធំហួសពីលទ្ធភាពថវិកាដែលមាន និងវិសាលភាពការងាររបស់ក្រុមប្រឹក្សាយោបល់ លេខាធិការដ្ឋានបានផ្តល់ការណែនាំ បញ្ជាក់ពីវិសាលភាព ក៏ដូចជាគោលបំណងជាក់លាក់នៃសកម្មភាពនេះជូនដល់កិច្ចប្រជុំ។ លេខាធិការដ្ឋានក៏បានផ្តល់ជូនជាឧទាហរណ៍ នូវសកម្មភាពចាំបាច់ជាក់លាក់ជាអាទិភាព និងទម្រង់ផែនការថវិកា ដើម្បីសម្រួលដល់ការរៀបចំ។ កិច្ចប្រជុំបានយល់ព្រមធ្វើផែនការឡើងវិញ នឹងផ្ញើជូនលេខាធិការដ្ឋាននៅថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៤ ដើម្បីបូកសរុប និងសុំការគាំទ្រថវិកា ពីកម្មវិធី UN-REDD។

*សរុបនៃអង្គប្រជុំ*

*សហប្រធាន បានថ្លែងអរគុណចំពោះសមាជិកក្រុមប្រឹក្សាយោបល់ ដែលបានចូលរួមក្នុងកិច្ចប្រជុំនេះ និងសង្ឃឹមថាក្រុមនឹងបន្តការងារយ៉ាងសកម្មក្នុងការអនុវត្តសកម្មភាព ជាពិសេសការប្រឹក្សាយោបល់ជាមួយក្រុមរបស់ខ្លួន និងអ្នកពាក់ព័ន្ធ។*

*ក្រុមប្រឹក្សាយោបល់ បានសម្រេចថានឹងមានប្រធានដឹកនាំអង្គប្រជុំប្តូរវេននៅកិច្ចប្រជុំលើកក្រោយ ដោយគោរពតាមតារាងបញ្ជីឈ្មោះសមាជិកក្រុមប្រឹក្សាយោបល់ ដែលលេខាធិការដ្ឋានបានរៀបចំ និងជូនភ្ជាប់ជាមួយកំណត់ហេតុនៃកិច្ចប្រជុំ។*

*កិច្ចប្រជុំលើកក្រោយ បានសម្រេចយកថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៨។ ប្រធានបទដែលនឹងយកទៅពិភាក្សារួមមាន៖ លក្ខខណ្ឌការងារ និងបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សាយោបល់ បទពិសោធន៍និងបញ្ហាប្រឈមរបស់សមាជិកក្រុម និងការពិនិត្យ ពិភាក្សាលើប្រធានបទនៃកិច្ចប្រជុំក្រុមការងាររេដ+ ដើម្បីជូនជាអនុសាសន៍ ឬ យោបល់។*

**អ្នកធ្វើកំណត់ហេតុ**

**ប្រធានក្រុមប្រឹក្សាយោបល់**

# កិច្ចប្រជុំលើកទី៤ក្រុមប្រឹក្សាយោបល់រេដ+កម្ពុជា

*ទីកន្លែងប្រជុំ:* សណ្ឋាគារសូហ្វីតែលភូគីត្រាភ្នំពេញ រាជធានីភ្នំពេញ

*កាលបរិច្ឆេទ:* ថ្ងៃទី២២ ខែមករា ឆ្នាំ២០១៨

*ពេលវេលា:* ៨:៣០នាទីព្រឹក - ១៧:០០ នាទី រសៀល

## របៀបវារៈកិច្ចប្រជុំ

| ពេលវេលា | ប្រធានបទពិភាក្សា | អ្នកសម្របសម្រួល |
|---|---|---|
| ០៨:០០ - ០៨:៣០ | - ចុះឈ្មោះអ្នកចូលរួម | - មន្ត្រីលេខាធិការដ្ឋាន |
| ០៨:៣០ - ០៩:០០ | - ការណែនាំខ្លួនអ្នកចូលរួម<br>- ការពិនិត្យកំណត់ហេតុកិច្ចប្រជុំលើកទី៣ | - សហប្រធានអង្គប្រជុំ |
| **០៩:៣០ - ០៩:៤៥** | - ***សម្រាកអាហារសម្រន់*** | |
| ០៩:០០ - ១១:០០ | - ការពិនិត្យ និងពិភាក្សាទៅលើប្រធានបទ និងឯកសារពិភា ក្សាក្នុងកិច្ចប្រជុំលើកទី៣ របស់ក្រុមការងាររេដ+កម្ពុជា<br>○ ការធ្វើបទបង្ហាញ<br>○ ការពិភាក្សា | - លោក លន់ គឹមហ៊ី |
| ១១:០០ - ១២:០០ | - ការពិនិត្យឡើងវិញពីការបំពេញតួនាទី ២ ជាCG និងជាTT | - កញ្ញា ហៀង ធី |
| **១២:០០ - ១៣:៣០** | ***សម្រាកអាហារថ្ងៃត្រង់*** | |
| ១៣:៣០ - ១៤:៣០ | - ការពិនិត្យនិងពិភាក្សាទៅលើផែនការយន្តការលំហូរព័ត៌មាន និងការផ្តល់យោបល់ត្រឡប់របស់ក្រុមប្រឹក្សាយោបល់ | - លោកលន់ គឹមហ៊ី |
| **១៤:៤០ - ១៥:០០** | - ***សម្រាកអាហារសម្រន់*** | |
| ១៥:០០ - ១៦:០០ | បន្តកិច្ចពិភាក្សាលើ៖<br>- ការពិនិត្យនិងពិភាក្សាទៅលើផែនការយន្តការលំហូរព័ត៌មាន និងការផ្តល់យោបល់ត្រឡប់របស់ក្រុមប្រឹក្សាយោបល់ | - លោកលន់ គឹមហ៊ី |
| ១៦:០០ - ១៦:៤៥ | - បញ្ហាផ្សេងៗ | - ប្រធានអង្គប្រជុំ |
| **១៦:៤៥ - ១៧:០០** | - **មតិបូកសរុបបិទអង្គប្រជុំ** | - **ប្រធានអង្គប្រជុំ** |

# កិច្ចប្រជុំលើកទី៤នៃក្រុមប្រឹក្សាយោបល់រេដ+កម្ពុជា

*ថ្ងៃទី២២ ខែមករា ឆ្នាំ២០១៤ សណ្ឋាគារសូហ្វីតែលភូគីត្រាភ្នំពេញ  រាជធានីភ្នំពេញ*

## បញ្ជីឈ្មោះអ្នកចូលរួម

| | | | | | |
|---|---|---|---|---|---|
| ០១ | Mr. Seak Sophat | សៀកសូផាត | គ្រឹះស្ថានអប់រំ(RUPP) | 016 506 888 | វត្តមាន |
| ០២ | Mr. Kim Soben | គឹមសុបិន្ត | គ្រឹះស្ថានអប់រំ(RUA) | 012 724 686 | វត្តមាន |
| ០៣ | Mr. Rith Bun Roeun | រឹតប៊ុនរឿន | សង្គមស៊ីវិល | 012 928 553 | វត្តមាន |
| ០៤ | Mr. Smeun Boreyroth | ស្មឿនបូរីរដ្ឋ | សង្គមស៊ីវិល | 012 637 686 | វត្តមាន |
| ០៥ | Ms. Hou Kalyan (Mr. Chheng Channy) | ហ៊ូ កល្យាណ (ឆេងចន្ទី) | អង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ | 012 839 955 | វត្តមាន (ជំនួស) |
| ០៦ | Mr. Kim Narong | សូផាសុគន្ធ ណារុង្គ | អង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ | 012 418 883 | វត្តមាន |
| ០៧ | Mr. Va Moeurn | វ៉ា មឿន | អង្គការមិនមែនរដ្ឋាភិបាលជាតិ | 012 782 536 | វត្តមាន |
| ០៨ | Mr. Chhith Sam Ath (Ms. Teng Rithiny) | ឈិតសំអាត (តេងរិទ្ធីនី) | អង្គការមិនមែនរដ្ឋាភិបាលជាតិ | 012 928 585 | វត្តមាន (ជំនួស) |
| ០៩ | Mr. Vong Dara | វង្សតារា | សហគមន៍តំបន់ការពារ(KKH) (សមាជិកបន្ថែម) | 097 727 8611/012 450 338 | វត្តមាន |
| ១០ | Mr. Sar Thlay | សារថ្លៃ | សហគមន៍ព្រៃឈើ (OMC) | 097 781 4199 | វត្តមាន |
| ១១ | Mr. Mao Nga | ម៉ៅ ង៉ា | សហគមន៍ព្រៃឈើ (SRP) | 097 912 4265 | អវត្តមាន |
| ១២ | Mr. Long So Chet | ឡុងសុចែត្រ | សហគមន៍នេសាទ (KCH) | 012 989 318/097 3320600 | វត្តមាន |
| ១៣ | Mr. Sao Theang | សៅធាង | សហគមន៍នេសាទ(SHV) | 097 358 6813 | វត្តមាន |
| ១៤ | Mr. Prum Sarath | ព្រុំសារ៉ាត | សហគមន៍តំបន់ការពារ(BTB) | 089 692 725 | វត្តមាន |
| ១៥ | Mr. Kean Hean | គានហ៊ាន | សហគមន៍តំបន់ការពារ(KTH) | 092 823 8 43/088 895 5060 | វត្តមាន |
| ១៦ | Mr. Nok Ven | ណក់ វ៉ែន | ជនជាតិដើមភាគតិច(MDK) | 098 756 168 | វត្តមាន |
| ១៧ | Mr. Chheut Chhorn | ធឹតឈន | ជនជាតិដើមភាគតិច(BTB) | 017 546 592 | អវត្តមាន |
| ១៨ | Mr. Sum Sokun | ស៊ុំ សុគន្ធ | វិស័យឯកជន | 015 518 111 | អវត្តមាន |
| ១៩ | Mr. Lu Chu-chang | លូ ឈូចាង | វិស័យឯកជន | 012 809 909 | អវត្តមាន |
| ២៤ | Ms. Thy Heang | ធី ហៀង | អ្នកសម្របសម្រួល | លេខាធិការដ្ឋានរេដ+ | |
| ២៥ | Ms. Duk Sireivathana | ឌុក សិរីវឌ្ឍនា | អ្នករៀបចំ | លេខាធិការដ្ឋានរេដ+ | |

| អ្នករៀបចំ និងផ្សេងៗ | | | | |
|---|---|---|---|---|
| ១៩ | Mr. Uy Kamal | អ៊ុយ កាម៉ាល | សហប្រធានអង្គប្រជុំ | រដ្ឋបាលព្រៃឈើ |
| ២០ | Mr. Lun Kimhy | លន់ គឹមហ៊ី | អ្នកសម្របសម្រួល | លេខាធិការដ្ឋានវេដ+ |
| ២១ | Ms. Pan Thida | ប៉ាន់ ធីតា | អ្នករៀបចំ | លេខាធិការដ្ឋានវេដ+ |
| ២២ | Mr. Teng Huort | តេងហួត | អ្នករៀបចំ | លេខាធិការដ្ឋានវេដ+ |
| ២៣ | Ms. Meas Somonika | មាសសុម៉ូនីកា | អ្នករៀបចំ | លេខាធិការដ្ឋានវេដ+ |

## លេខរៀង ប្រធានបទ្ធរទេនសម្របសម្រួល កិច្ចប្រជុំក្រុមប្រឹក្សាយោបល់

| | | | | |
|---|---|---|---|---|
| ០១ | Mr. Seak Sophat | សៀកសុផាត | គ្រឹះស្ថានអប់រំ (RUPP) | 016 506 888 |
| ០២ | Mr. Kim Soben | គឹមសុបិន្ត | គ្រឹះស្ថានអប់រំ (RUA) | 012 724 686 |
| ០៣ | Mr. Rith Bun Roeun | រឹតប៊ុនរឿន | សង្គមស៊ីវិល | 012 928 553 |
| ០៤ | Mr. Smeun Boreyroth | ស្មឿនបូរីរដ្ឋ | សង្គមស៊ីវិល | 012 637 686 |
| ០៥ | Ms. Hou Kalyan | ហ៊ូ កល្យាណ | អង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ | 012 839 955 |
| ០៦ | Mr. Kim Narong | គីម ណារុង្គ | អង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ | 012 418 883 |
| ០៧ | Mr. Va Moeurn | វ៉ា មឿន | អង្គការមិនមែនរដ្ឋាភិបាលជាតិ | 012 782 536 |
| ០៨ | Ms. Teng Rithiny | តេងរិទ្ធីនី | អង្គការមិនមែនរដ្ឋាភិបាលជាតិ | 012 928 585 |
| ០៩ | Mr. Vong Dara | វង្សតារា | សហគមន៍តំបន់ការពារ (KKH បន្ថែម) | 097 727 8611/012 450 338 |
| ១០ | Mr. Sar Thlay | សារថ្លៃ | សហគមន៍ព្រៃឈើ (OMC) | 097 781 4199 |
| ១១ | Mr. Mao Nga | ម៉ៅ ង៉ា | សហគមន៍ព្រៃឈើ (SRP) | 097 912 4265 |
| ១២ | Mr. Long So Chet | ឡុងសុចេត្រ | សហគមន៍នេសាទ (KCH) | 012 989 318/097 3320600 |
| ១៣ | Mr. Sao Theang | សៅធាង | សហគមន៍នេសាទ (SHV) | 097 358 6813 |
| ១៤ | Mr. Prum Sarath | ព្រុំសារ៉ាត | សហគមន៍តំបន់ការពារ (BTB) | 089 692 725 |
| ១៥ | Mr. Kean Hean | គានហ៊ាន | សហគមន៍តំបន់ការពារ (KTH) | 092 823 8 43/088 895 5060 |
| ១៦ | Mr. Nok Ven | ណក់ វ៉ែន | ជនជាតិដើមភាគតិច (MDK) | 098 756 168 |
| ១៧ | Mr. Chheut Chhorn | ធឹតឈន | ជនជាតិដើមភាគតិច (BTB) | 017 546 592 |
| ១៨ | Mr. Sum Sokun | ស៊ុំ សុគន្ធ | វិស័យឯកជន | 015 518 111 |
| ១៩ | Mr. Lu Chu-chang | លូ ឈូឆាង | វិស័យឯកជន | 012 809 909 |

# ការពិភាក្សាស្ដីពីជម្រើសពផ្សេងគ្នា ពាក់ព័ន្ធនឹងការអនុវត្តរេដ+

កិច្ចប្រជុំលើកទី៣ក្រុមការងាររេដ+កម្ពុជា
សណ្ឋាគារ
ថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៤



# រេដ+នៅថ្នាក់ផ្សេងគ្នា
# (REDD+ at different scale)

- រេដ+ផ្អែកតាមគម្រោង (Project)
- រេដ+ថ្នាក់ក្រោមជាតិ (Subnational)
- រេដ+ថ្នាក់ជាតិ (National)





# ភាគច្រើនបទពិសោធន៍ដែលមានគឺរេដ+ផ្អែកតាមគម្រោង ( REDD+ Project )

- គម្រោងគឺមានការយល់ដឹងគ្រប់គ្នា ដូចជាៈ រដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធ
- គម្រោងងាយស្រួលពន្យល់ពីទស្សនទាន មានដែនកំណត់ និងមានអ្នកពាក់ព័ន្ធជាក់លាក់
- មិនធំហួស និងចាត់ចែងថវិកាដោយផ្ទាល់
- ងាយស្រួលរាយការណ៍ជូនអ្នកផ្តល់ជំនួយ



# រេដ+នៅថ្នាក់ផ្សេងគ្នា ហេតុមានសារសំខាន់?

- ការផ្តល់ថវិកាជារឿងសំខាន់ និងការប្រើប្រាស់វិធីសាស្រ្តផ្សេងគ្នា ដែលនាំឲ្យមាន ឱកាស និងការលំបាកផ្សេងគ្នា។
- មុន COP19 ការទទួលបានថវិកា យើងមានតែទីផ្សារកាបូនស្ម័គ្រចិត្តមួយមុខប៉ុណ្ណោះ
- ក្រោយ COP19 យើងមានឱកាសច្រើនកំពុងលេចឡើង ដែលឱកាសខ្លះត្រូវការពេលវេលាច្រើនឆ្នាំ





# លទ្ធភាពនៃថវិការេដ+

(Possible funding)



- ថវិកាពីយន្តការ UNFCCC REDD+
- ថវិកាពី Green Climate Fund
- ថវិកាពី Bilateral agreements
- ថវិកាពី Forest Carbon Partnership Facility
- ថវិកាពីទីផ្សារកាបូនស្ម័គ្រចិត្ត (Voluntary Carbon Market)
- ថវិកាពីទីផ្សារកាបូនដទៃទៀត (California, Japan, China, Korea)





# លទ្ធភាពនៃថវិការេដ+(ត)
## (Possible funding)

- ថវិកាពីយន្តការ UNFCCC REDD+
  - មិនទាន់បង្កើតនៅឡើយ ប្រហែលនៅឆ្នាំ២០២០ ជាផ្នែកមួយនៃកិច្ចព្រមព្រៀងស្តីពីការប្រែប្រួលអាកាសធាតុ
  - តើត្រូវអនុវត្តតាមការសម្រេច UNFCCC REDD+ ឬយ៉ាងណា?





# លទ្ធភាពនៃថវិការេដ+( ត )
(Possible funding)

- ថវិកាពី Green Climate Fund
  - បានបង្កើតហើយប៉ុន្តែត្រូវការបង្កើតវិធានក្នុងការផ្តល់ថវិកា
  - រេដ+ត្រូវបានលើកឡើង ជាផ្នែកមួយនៃការចាប់ផ្តើម
  - ត្រូវអនុវត្តតាមការសម្រេចរបស់ UNFCCC ស្តីពី REDD+
  - កន្លងមកមានការខ្វះខាតលុយក្នុងការបង្កើតថវិកា





# លទ្ធភាពនៃថវិការេដ+( ត )
## (Possible funding)

- ថវិកាពី Bilateral agreements
  - ងាយយល់ ឧទាហរណ៍ រវាង Norway ជាម្ចាស់ជំនួយនិងប្រទេសនានា (Brazil, Guyana, Indonesia and Vietnam)
  - ភាគច្រើនត្រូវអនុវត្តតាមការសម្រេចរបស់ UNFCCC ស្តីពី REDD+





# លទ្ធភាពនៃថវិការេដ+( ត )

## (Possible funding)

- ថវិកាពី Forest Carbon Partnership Facility
  - បានបង្កើតទៅតាមក្របខណ្ឌរបស់ខ្លួន ដោយស្របតាមការសម្រេចរបស់ UNFCCC ស្តីពី REDD+
  - មានកំណត់ត្រឹម ៥ ទៅ ៨ ប្រទេសប៉ុណ្ណោះ។





# លទ្ធភាពនៃថវិការេដ+( ត )

(Possible funding)

- ថវិកាពីទីផ្សារកាបូនស្ម័គ្រចិត្ត Voluntary Carbon Market
  - ➢ មានស្តង់ដារច្រើនផ្អែកតាមទំហំគម្រោង ទៅអនាគតប្រហែលជា ថ្នាក់ក្រោមជាតិ
  - ➢ តម្លៃប្រែប្រួលតាមតម្រូវការ និងផ្គត់ផ្គង់ ឥណទានកាបូន
  - ➢ វិធីសាស្ត្រផ្សេងគ្នា តាមការសម្រេចរបស់ UNFCCC ស្តីពី REDD+





# លទ្ធភាពនៃថវិការេដ+ ( ត )

## (Possible funding)

- ថវិកាពីទីផ្សារកាបូនដទៃទៀត(California, Japan, China , Korea)
  - California: កំពុងពិភាក្សា ពីការរួមបញ្ចូលរេដ+
  - Japan:  JCM កំពុងបង្កើត
  - China: មានទីផ្សារកាបូនប៉ុន្តែកន្លងមកមិនជាប់ទាក់ទងនឹងរេដ
  - Korea: មានផែនការឲ្យមានទីផ្សារកាបូនពីឆ្នាំ ២០១៥ តទៅ (មិនដឹងច្បាស់ពីតួនាទីរបស់រេដ+)





# លទ្ធភាពនៃថវិការេដ+( គ )

(Possible funding)



- ថវិកាពី
- 
- ថ
- ថវិកាពី Forest ip Facility
- ថវិកាពីទីផ្ស ntary Carbon Market)
- ថវិកា Japan, China, Korea)

ថ្នាក់ក្រោមជាតិ
និងថ្នាក់ជាតិ

ថ្នាក់គម្រោង និង
ថ្នាក់ក្រោមជាតិ





# លទ្ធភាពនៃថវិការេដ+(គ)
## (Possible funding)

- បញ្ហាត្រូវដោះស្រាយពេលខាងមុខ
  - ➢ បើតាម UNFCCC រេដ+ថ្នាក់ក្រោមជាតិ គ្រាន់តែជាការបណ្ដោះអាសន្ន
  - ➢ រេដ+ថ្នាក់ក្រោមជាតិក្រោមប្រព័ន្ធទីផ្សារស្ម័គ្រចិត្ត ទំនងខុសគ្នាពី រេដ+ថ្នាក់ក្រោមជាតិក្រោមប្រព័ន្ធUNFCCC





# ការស្នាក់ស្នើរបស់កម្ពុជា និងបណ្តាប្រទេសនានា ដែលអនុវត្តរេដ+

- ការអនុវត្តតាមវិធីសាស្រ្ត និងតម្រូវការផ្សេងគ្នា ក្នុងពេលតែមួយ នឹងនាំឲ្យមានការភ័ន្តច្រឡំ ក្នុងការត្រៀមលក្ខណៈ សម្រាប់រេដ+នៅថ្នាក់ជាតិ ដែលក្នុងនោះនឹងមានហានិភ័យ ចំពោះការខិតខំប្រឹងប្រែង និងការចំណាយដោយគ្មានប្រយោជន៍ និងពន្យារពេលក្នុងការចូលរួមការទទួលបានថវិកាពីរេដ+។





# ការស្នាក់ស្នើរបស់កម្ពុជា និងបណ្តាប្រទេសនានា ដែលអនុវត្តរេដ+(ត)

- វិធីសាស្រ្តគម្រោងដែលមានស្រាប់ ភាគច្រើន មិនសមស្របនឹងការសម្រេច របស់ UNFCCC ។ ន្យារពេលក្នុងការចូលរួមការទទួលបានថវិកាពីរេដ+។
- គម្រោងតែងបង្កើតឡើងសម្រាប់រយៈពេលវែង(៣០ឆ្នាំ)





# សំនួរសម្រាប់កម្ពុជា

- តើជម្រើសថវិកាណាមួយ ដែលអាចយកបាន?
- តើរេដ+ណាមួយ ងាយស្រួល ធ្វើទៅបាន និងស្របតាមនយោបាយ?
- តើទៅអនាគត រេដ+ណាមួយសមស្របសម្រាប់កម្ពុជា?
- បើសម្រេចយករេដ+ណាមួយ តើត្រូវធ្វើអ្វីខ្លះ?





# រេដ+នៅថ្នាក់ផ្សេងគ្នា
# (REDD+ at different scale)

- រេដ+ផ្អែកតាមគម្រោង (Project)
- រេដ+ថ្នាក់ក្រោមជាតិ (Subnational)
- រេដ+ថ្នាក់ជាតិ (National)





# សូមអរគុណ!

Mr. Peter Iversen

Email: peter.iversen@undp.org

Website: www.cambodia-redd.org





# ឯកសារពិភាក្សា

ឯកសារពិភាក្សានេះ មានបំណងស្វែងរកការសម្រេចចិត្តទៅលើជម្រើស៣ផ្សេងគ្នា ពាក់ព័ន្ធនឹងរេដ+៖ ជម្រើសទី១)រេដ+ផ្អែកតាមគម្រោង (Project based REDD+) ជម្រើសទី២)រេដ+ថ្នាក់ក្រោមជាតិ (Sub-national REDD+) និង ជម្រើសទី៣)រេដ+ថ្នាក់ជាតិ (National REDD+) ដោយរួមបញ្ចូលនូវការពិចារណាផងដែរពីបញ្ហាថវិកា។

ឯកសារពិភាក្សានេះមិនបានគ្របដណ្តប់នូវគ្រប់ទិដ្ឋភាពឡើយ ព្រោះថាឯកសារនេះ ផ្តល់ត្រឹមព័ត៌មានបច្ចេកទេស ប៉ុន្តែមានបំណងផ្តល់នូវការពិនិត្យមើលលើទិដ្ឋិភាពសំខាន់សម្រាប់ការធ្វើសេចក្តីសម្រេចចិត្ត។ ឯកសារពិភាក្សានេះ ក៏បានផ្តល់នូវចំណុច វិជ្ជមាន និងអវិជ្ជមានផងដែរពាក់ព័ន្ធនឹងជម្រើសនីមួយៗ និងចំណុចមិនដឹងច្បាស់ ដែលធ្វើឲ្យយើងមិនអាចព្យាករណ៍បានពីលទ្ធភាពនៃមូលនិធិរេដ+នាពេលអនាគត។

ឯកសារពិភាក្សានេះ ក៏បានបញ្ចូលបន្ថែមផងដែរនូវគំនូសបំព្រួញនៃការសម្រេចចិត្ត ដើម្បីជួយផ្តល់ជាគំនិតសម្រាប់ធ្វើការសម្រេចចិត្ត និងផ្នែកចុងក្រោយមានផ្តល់សំណួរសំខាន់ៗ ដែលផ្តោតលើភាពខុសគ្នារវាង រេដ+ផ្អែកលើគម្រោង និង រេដ+ក្របខណ្ឌអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីបម្រែបម្រួលអាកាសធាតុ (UNFCCC)។

## ចំណុចវិជ្ជមាន និងអវិជ្ជមាន នៃជម្រើសផ្សេងៗគ្នា

***ជម្រើសទី១៖រេដ+ផ្អែកតាមគម្រោង*** (Project based REDD+)

- *ចំណុចវិជ្ជមាន*

*គ្រប់គ្នាទាំងរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធ ងាយយល់ពីគម្រោង។ គម្រោងងាយស្រួលពន្យល់ពីទស្សនទាន មានដែនកំណត់ និងត្រូវការអ្នកពាក់ព័ន្ធជាក់លាក់មិនធំហួស និងចាត់ចែងថវិកាដោយផ្ទាល់។*

- *ចំណុចអវិជ្ជមាន*

*គម្រោងមិនត្រឹមតែចំណាយអន្តរកាលខ្ពស់ អាស្រ័យតាមទំហំប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងមានវិធានស្មុគស្មាញដោយសារតែតម្រូវការដែលភ្ជាប់ជាមួយនិងការអនុវត្តគម្រោងដូចជា: តំបន់*

លេចធ្លាយ តំបន់ទ្រនាប់។ ថែមលើសពីនេះ ថវិកាទទួលបាន គឺតាមរយៈការលក់ឥណទានកាបូន ដែលបានពីទីផ្សារកាបូនស្ម័គ្រចិត្ត។ ព្យាករណ៍សម្រាប់ពេលខាងមុខឃើញថា មានការផ្គត់ផ្គង់ ឥណទានកាបូនច្រើន ប៉ុន្តែតំរូវការ មានភាពមិនច្បាស់លាស់ ដែលនឹងមានការលំបាកក្នុងការ លក់ឥណទានកាបូន និងមានបញ្ហាដល់ភាពរស់រានមានជីវិតរបស់គម្រោងរេដ+។ ម៉្យាងទៀត គម្រោងមិនអាចដោះស្រាយឬសគល់នៃកត្តាដែលនាំឲ្យបាត់បង់ និងរេចរិលព្រៃឈើ ព្រមទាំង មិនអាចផ្តល់ថវិកាដល់ការគ្រប់គ្រងដ៏មានប្រសិទ្ធិភាពសំខាន់ៗ លើវិស័យព្រៃឈើឡើយ ឧទាហរណ៍ ដូចជាកម្មវិធីព្រៃឈើជាតិ និងកម្មវិធីស្រដៀងគ្នាដទៃទៀតរបស់រដ្ឋបាលព្រៃឈើ និងអគ្គនាយកដ្ឋាន រដ្ឋបាលការពារអភិរក្សធម្មជាតិ។

ក្នុងករណីដែលកម្ពុជា សម្រេចយកជម្រើសទី២(រេដ+ថ្នាក់ក្រោមជាតិ) ឬ ជម្រើសទី៣ (រេដ+ថ្នាក់ជាតិ)ស្របតាមក្របខណ្ឌអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីបម្រែបម្រួលអាកាសធាតុ នោះគម្រោងរេដ+ដែលមានកំរិតយោង (REL) បង្កើតឡើងសម្រាប់ទីផ្សារកាបូនស្ម័គ្រចិត្ត ឬ ក្រោម យន្តការទីផ្សារកាបូនដទៃទៀត នឹងទំនងជាតម្រូវឲ្យធ្វើឡើងវិញ។ ការរក្សាគម្រោងដែលមានស្រាប់ នៅក្នុងគណនីថ្នាក់ក្រោមជាតិ ឬ ថ្នាក់ជាតិ នឹងបង្កើនឲ្យមានចំណាយអន្តរកាល ដោយសារការ ត្រួតពិនិត្យ រាយការណ៍ និងការផ្ទៀងផ្ទាត់ទ្វេដង។ ដូច្នេះយើងត្រូវសម្រេច ថាតើត្រូវដោះស្រាយ ដោយរបៀបណាចំពោះគម្រោងរេដ+ដែលមានស្រាប់ ។

អ្នកផ្តល់ជំនួយ ដែលជួយផ្តល់ថវិកាដល់គម្រោងរេដ+ ទំនងជាប្តូរការអនុវត្ត ឲ្យស្របតាម វិធានដែលបានព្រមព្រៀងក្រោមក្របខណ្ឌអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីបម្រែបម្រួលអា កាសធាតុ (UNFCCC) ។

- <u>ចំណុចមិនដឹងច្បាស់</u>

វិធានរបស់UNFCCCសម្រាប់រេដ អាចនឹងមិនបើកចំហសម្រាប់ រេដ+ផ្អែកតាមគម្រោង (Project based REDD)ឡើយ។ ការសម្រេចនាពេលអនាគត ស្តីពីទីផ្សារកាបូន អាចនឹងអនុញ្ញាត ឲ្យមានរេដ+ផ្អែកតាមគម្រោង។ បណ្តាប្រទេសមួយចំនួន នឹងគាំទ្ររេដ+ផ្អែកតាមគម្រោង ក្នុងគោលបំណង ផ្តល់ភាពអាចបត់បែនបាន ទន្ទឹមនឹងនេះ បណ្តាប្រទេសដទៃនឹងជំទាស់នឹងការសម្រេចនេះ ដោយសារ មើលឃើញថា រេដ+ផ្អែកតាមគម្រោង មិនបានរួមវិភាគទាន ដល់ការកាត់បន្ថយបម្រែបម្រួលអាកាស ធាតុពិភពលោក។

**ជម្រើសទី២៖រេដ+ថ្នាក់ក្រោមជាតិ**( Sub-national REDD+ )

*រេដ+ថ្នាក់ក្រោមជាតិ អាចជាវិធានការបណ្ដោះអាសន្ន ដែលអនុញ្ញាតក្រោមវិធានរេដ+ របស់ UNFCCC។ ក្នុងខណៈពេលបណ្ដោះអាសន្ន និងរេដ+ថ្នាក់ក្រោមជាតិ មិនទាន់បានកំណត់ រេដ+ថ្នាក់ក្រោមជាតិ គួរគ្របដណ្ដប់យ៉ាងតិច ខេត្តណាមួយ ឬ ទិដ្ឋភាពព្រៃទាំងមូល* (Forest Landscape) *ដែលគ្របដណ្ដប់ខេត្តជាច្រើន។ ដោយយោងតាមវិធាន រេដ+ថ្នាក់ក្រោមជាតិ ទាមទារឲ្យមានការត្រួតពិនិត្យព្រៃឈើកំរិតជាតិ ក្នុងគោលបំណងការពារការលេចធ្លាយ។ ជាមួយនឹងការអនុវត្ត រេដ+ថ្នាក់ក្រោមជាតិ ប្រទេសនីមួយៗត្រូវមានផែនការ ប្ដូរទៅអនុវត្ត រេដ+ថ្នាក់ជាតិ។*

- *ចំណុចវិជ្ជមាន*

*អនុញ្ញាតឲ្យមានគណនី និងប៉ាន់ប្រមាណលទ្ធផលលើតំបន់ដែលមានផ្ទៃដីតូចជាងទឹកដីរបស់ជាតិ។ រេដ+ថ្នាក់ក្រោមជាតិ អាចធ្វើឲ្យងាយស្រួលក្នុងការអនុវត្ត ឧទាហរណ៍ៈ ការបែងចែកផលប្រយោជន៍។ អនុវត្តតាមវិធាន* UNFCCC *ប្រវត្តិនៃការបំភាយឧស្ម័នអាចត្រូវបានប្រើប្រាស់ ដើម្បីបង្កើតកម្រិតយោង និងពុំមានការទាមទារបន្ថែម ដើម្បីដោះស្រាយបន្ថែមដូចរេដ+ផ្អែកតាមគម្រោងឡើយ។*

*អ្នកផ្ដល់ជំនួយ និងមូលនិធិអាកាសធាតុបៃតង* (Green Climate Fund) *មានបំណងគាំទ្រយ៉ាងខ្លាំង ដល់ប្រទេសមួយចំនួន ឲ្យប្ដូរមកអនុវត្តតាមវិធានទាំងស្រុង ដែលបានព្រមព្រៀងដោយ* UNFCCC *។ ការគាំទ្រនេះ រួមបញ្ចូលទាំងការអនុវត្ត រេដ+ថ្នាក់ក្រោមជាតិ ឬ លើតំបន់ព្រៃឈើទាំងមូល ដែលគ្របដណ្ដប់ខេត្តច្រើន ដែលកាន់តែទាក់ទាញថែមទៀតសម្រាប់ម្ចាស់ជំនួយ។*

- *ចំណុចអវិជ្ជមាន*

*ដោយសារតែការត្រួតពិនិត្យទាមទារធ្វើនៅកម្រិតជាតិ ដូច្នេះភាពខុសគ្នារវាងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ គឺគណនី និងការបែងចែកផលប្រយោជន៍នូវលទ្ធផល។ កម្រិតយោងនឹងគ្របដណ្ដប់ តែលើតំបន់នៃថ្នាក់ក្រោមជាតិ ហើយលទ្ធផលពីក្រៅតំបន់ថ្នាក់ក្រោមជាតិ នឹងមិនត្រូវបានយកមកពិចារណាឡើយ មានន័យថាឥណទានកាបូនឌីអុកស៊ីត* ($CO_2$) *ដែលបានពីការកាត់បន្ថយការរេចរិលព្រៃឈើ ក្រៅតំបន់ថ្នាក់ក្រោមជាតិ មិនត្រូវបានប្រកាស(គណនា) ប៉ុន្តែការលេចធ្លាយនឹងត្រូវបានយកមកគណនា។ នេះជាការគិតគូរតែលើចំណុចអវិជ្ជមាន ដោយមិនបានទទួលផលប្រយោជន៍ ពីចំណុចវិជ្ជមានឡើយ។*

▪ *<u>ចំណុចមិនដឹងច្បាស់</u>*

*ដោយសាររេដ+ថ្នាក់ក្រោមជាតិ ជាជំរើសបណ្តោះអាសន្ន ដូច្នេះនៅមិនច្បាស់ថាតើឥណទានកាបូន ដែលបង្កើតឡើងដោយរេដ+ថ្នាក់ក្រោមជាតិ អាចត្រូវបានប្រើប្រាស់ដោយទីផ្សារកាបូនកាតព្វកិច្ចសាកល ឬ រេដ+ថ្នាក់ក្រោមជាតិ គ្រាន់តែជាសកម្មភាពសាកល្បងបង្ហាញ សម្រាប់ការគាំទ្ររបស់ម្ចាស់ជំនួយប៉ុណ្ណោះ?*

***ជម្រើសទី៣៖រេដ+ថ្នាក់ជាតិ***( National REDD+ )

*តាំងពីពេលចាប់ផ្តើមដំបូង* UNFCCC REDD+ *ត្រូវបានពិព៌ណនាថាជាការរួមវិភាគទានរបស់ជាតិ សម្រាប់ការកាត់បន្ថយបម្រែបម្រួលអាកាសធាតុពិភពលោក ដោយមានគណនីជាតិសម្រាប់កំណត់ការបំភាយ ឬ ស្រូបឧស្ម័នផ្ទះកញ្ចក់ ដោយប្រៀបធៀបនឹងកម្រិតយោងជាតិ និងផ្តល់មកវិញនូវការលើកទឹកចិត្តដោយប្រព័ន្ធអន្តរជាតិ សម្រាប់ប្រទេសចូលរួមដែលបានបង្កើត និងរាយការណ៍ពីលទ្ធផលជាវិជ្ជមាន។*

▪ *<u>ចំណុចវិជ្ជមាន</u>*

*ប្រព័ន្ធត្រួតពិនិត្យជាតិនឹងធ្វើឲ្យប្រាកដថា លទ្ធផលទាំងអស់ដែលសម្រេចបានដោយប្រទេសខ្លួនពិតជាបានរួមវិភាគទាន ដោយមិនចាំបាច់មានប្រព័ន្ធគណនី ដើម្បីដោះស្រាយបញ្ហាលេចធ្លាយនៅថ្នាក់ជាតិឡើយ។ អនុវត្តតាមវិធាន* UNFCCC *ប្រវត្តិនៃការបំភាយឧស្ម័នអាចនឹងត្រូវបានប្រើប្រាស់សម្រាប់ការបង្កើតកំរិតយោង និងមិនមានការទាមទារបន្ថែម ដើម្បីដោះស្រាយដូចគម្រោងនោះទេ។*

*ហិរញ្ញវត្ថុរេដ+នៅថ្នាក់ជាតិ អាចរួមវិភាគទានដល់សេចក្តីត្រូវការកម្រិតគោលនយោបាយដើម្បីសម្រេចលទ្ធផលនានា ឧទាហរណ៍ ការអនុវត្តកម្មវិធីជាតិ ដូចជាកម្មវិធីព្រៃឈើជាតិជាដើម។*

*អ្នកផ្តល់ជំនួយ និងមូលនិធិអាកាសធាតុបៃតង* (Green Climate Fund)*មានបំណងគាំទ្រយ៉ាងខ្លាំង ដល់ប្រទេសមួយចំនួន ឲ្យប្តូរមកអនុវត្តតាមវិធានទាំងស្រុង ដែលបានព្រមព្រៀងដោយ* UNFCCC*។ កន្លងមកមានប្រទេសពីរ ឬ បីប៉ុណ្ណោះ ដែលអនុវត្តតាមទិសដៅនេះ ប៉ុន្តែរេដ+ផ្អែកតាមគម្រោង* (Project based REDD+) *បានអនុវត្តនៅប្រទេសជាច្រើន ដោយសារនេះជាជម្រើសតែមួយគត់ ដែលមានភាពងាយស្រួលជាងព្រោះវាស្ថិតក្រោមគម្រោង ។*

▪ *<u>ចំណុចអវិជ្ជមាន</u>*

លទ្ធផល និងផលប្រយោជន៍ ត្រូវបានភ្ជាប់ជាមួយនឹងការអនុវត្តថ្នាក់ជាតិ ដែលនឹងត្រូវរួមបញ្ចូលអ្នកពាក់ព័ន្ធជាច្រើន នឹងធ្វើឲ្យការអនុវត្តមានភាពស្មុគស្មាញ។

- <u>ចំណុចមិនដឹងច្បាស់</u>

ការចរចារស្តីពីកិច្ចព្រមព្រៀងបម្រែបម្រួលអាកាសធាតុក្រោយឆ្នាំ២០២០ កំពុងបន្ត និងការរួមបញ្ចូលរេដ+ នៅមិនទាន់ដឹងច្បាស់ ប៉ុន្តែមានការគាំទ្រដោយប្រទេសភាគច្រើន។ សំនួរភាគច្រើនចោទសួរថាតើរេដ+នឹងត្រូវផ្តល់ថវិកាដោយរបៀបណា? ជាថវិកា ឬ ជាទីផ្សារកាបូន ឬ ជាជាការរួមគ្នាទាំងពីរ។ ភាគច្រើនទំនងជាការផ្តល់ថវិកា ដោយអ្នកផ្តល់ជំនួយ ទៅបណ្តាប្រទេស ផ្អែកតាមលទ្ធផលរេដ+សម្រាប់មុនឆ្នាំ២០២០។

## គំនូសបំព្រួញនៃការសម្រេចចិត្ត




## ហេតុអ្វីសំនួរទាំងនេះមានសារសំខាន់

វិធីសាស្ត្រ និងវិធានរេដ+ផ្អែកតាមគម្រោង និងរេដ+តាមវិធានUNFCCC មានភាពខុសគ្នាដូច្នេះការកសាងសមត្ថភាពត្រូវឆ្លើយតបតាមវិធីសាស្ត្រ និងវិធានទាំងនោះ បើមិនដូច្នេះទេ យើងនឹងបង្កឲ្យមានការភ័ន្តច្រឡំ ដល់អ្នកពាក់ព័ន្ធ។

ប្រសិនបើកម្ពុជាយឺតយ៉ាវក្នុងការសម្រេចចិត្តត្រៀមខ្លួនចូលរួមតាមវិធាន UNFCCC ការពន្យារពេលនៃការសម្រេចចិត្តនេះ និងការបង្កើតបន្ថែមរេដ+ផ្អែកតាមគម្រោង នឹងបង្កឲ្យភាពស្មុគស្មាញបន្ថែមទៀត។

បញ្ហាសំខាន់មួយទៀតគឺកម្រិតយោង។ កម្រិតយោងគឺជាការបំភាយនាពេលអនាគត ដែលត្រូវប្រៀបធៀប និងជាពិសេស ពាក់ព័ន្ធនិងរេដ+។

ដោយសារការប្រើប្រាស់វិធីសាស្ត្រខុសគ្នាក្នុងការកំណត់កម្រិតយោង នោះនឹងមិនមានន័យអ្វីឡើយ ប្រសិនបើប្រៀបធៀបជាមួយនឹងកម្រិតយោងរបស់រេដ+ផ្អែកតាមគម្រោង។ ការធ្វើសមាហរណកម្មគម្រោងទៅក្នុង រេដ+ថ្នាក់ជាតិ ឬ រេដ+ថ្នាក់ក្រោមជាតិ មានការលំបាក។ ការចែករំលែកកម្រិតយោង UNFCCC រវាងគម្រោងរេដ+ផ្សេងគ្នា និងការអនុវត្តនៅថ្នាក់ជាតិ អាចធ្វើទៅបាន ប៉ុន្តែមិនអាចបង្កើនកម្រិតយោងសរុបបានឡើយ។

ទាំងរេដ+តាមគម្រោង និងរេដ+ UNFCCC មិនអនុញ្ញាតឲ្យគណនាទ្វេដងបានឡើយ មានន័យថា ការកាត់បន្ថយការបំភាយតែមួយដូចគ្នា មិនអាចលក់ ឬ ទទួលរង្វាន់ទ្វេដងឡើយ។ ទាំងនេះនឹងនាំឲ្យមានសំនួរថា តើត្រូវរក្សាទុក ការត្រួតពិនិត្យគម្រោង ការរាយការណ៍ និងការផ្ទៀងផ្ទាត់ ដែលជាចំណាយបណ្ដោះអាសន្ន ព្រោះឥណទាននឹងផ្ដល់តាមរយៈ UNFCCC តែមួយប៉ុណ្ណោះ។

United Nations Framework Convention on Climate Change

# UNFCCC REDD-plus

Phnom Penh, Cambodia, January 2014

***Dirk Nemitz, Associate Programme Officer***

UNFCCC secretariat, MDA programme

## The way to Bali

- 2002: Avoided deforestation was not included in the CDM (only afforestation/reforestation)
- 2005: “Reducing emissions from deforestation in developing countries” introduced to COP 11 agenda by PNG, Costa Rica and 8 supporting countries
- 2007: COP 13 in Bali adopts decision 2/CP.13 and lays the foundation for REDD-plus

# The way to Cancun

- 2009: Copenhagen decision 4/CP.15
- 2010: Cancun decision 1/CP.16:
  - 5 REDD-plus activities
  - Elements: national strategy, RL, NFMS, SIS
  - Safeguards
  - Phased approach, national level

# The way to Warsaw

- 2011: Durban 2/CP.17 on results-based REDD-plus finance
- 12/CP.17 on:
    - guidance for safeguards IS, summary
    - Modalities for RLs
- 2012: Doha decision 1/CP.18 (work programme on results-based finance, and coordination of support)

# NFMS

- NFMS in line with IPCC guidance and guidelines, and in the context of adequate and predictable support
- Provide data and information that are transparent, consistent over time, and suitable for MRV
- Building upon existing systems while being flexible and allowing for improvement, reflecting the phased approach

# Timing & Frequency of Safeguards Summary

- Opens a new channel to provide the summary (REDD Web Platform)
- Timing: after start of implementation of activities 1/CP.16, paragraph 70
- Frequency: in line with national communications (and voluntarily via the REDD Web Platform)

# Drivers of deforestation and forest degradation

- Encourages Parties, organizations and the private sector to take action to reduce the drivers
- Also encourages to continue work to address drivers, and to share information
- Further encourages developing country Parties to take note of the information shared

# Technical assessment of reference levels

- Technical assessment is a MUST (starts a new process at UNFCCC)
- Invites Parties and relevant international organizations to support capacity-building for development and assessment of RLs (areas may be identified in TAs)

# MRV

- Consistent with UNFCCC methodological guidance, data & information transparent, and consistent with RL
- Results to be provided via BURs in technical annex (voluntarily and in the context of results-based payments), expressed in tonnes CO2 eq per year
- Two additional LULUCF experts in TTE for ICA, to develop a technical report, including their analysis of the technical annex and areas for technical improvement

# Coordination of support

- Invites interested Parties to designate a national entity or focal point
- Liaison with secretariat, and may be nominated to receive and obtain results-based payments
- Encourages national focal points to meet on a voluntary basis in order to discuss needs and functions in order to address issues related to the coordination of support
- Meeting may seek input, incl. from international orgs.

# Results-based finance (1 of 2)

- Connects results-based finance to MRV, safeguards summary
- Encourages financing entities, including GCF in a key role, to channel adequate and predictable results-based finance in a fair and balanced manner
- Also encourages to apply UNFCCC methodological guidance (Requests for GCF!)

# Results-based finance (2 of 2)

- Establishes information hub on REDD Web Platform, to publish information on the results and corresponding results-based payments

- Secretariat to organize expert meeting in 2014

# Implications (1 of 2)

- New guidance on NFMS, SGs, Drivers, TA of RLs and MRV provides clarity
- RLs can be submitted to UNFCCC for facilitative, non-intrusive, technical exchange (and updated), expert nomination
- Information on SGs, drivers, national strategies, etc. can be submitted to UNFCCC
- REDD Web Platform and technical discussion forum

# Implications (2 of 2)

- Invites Parties and relevant international organizations to support capacity-building for development and assessment of RLs
- REDD Parties may designate a national entity or focal point to serve as a liaison with UNFCCC, and may also be nominated to obtain results-based payments
- Finance decision with a clear signal to the GCF, and others, to collectively channel adequate and predictable results-based finance in a fair and balanced manner

# Thank you for your attention!

Questions? **dnemitz@unfccc.int**

Websites:

**1) http://unfccc.int/redd**

2) http://www.unfccc-redd-forum.net/